ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧២៤៣ សហវ.អថ

ថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** ករណីសំណើសុំដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តថវិកាដំណើរការសាលារៀនសាធារណៈ ចាប់ពីឆ្នាំ ២០១៩ និងឆ្នាំបន្តបន្ទាប់ ។

**យោង:** លិខិតលេខ ៦៤៤៧ អយក.ហវ ចុះថ្ងៃទី ០៣-១២-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា ដើម្បីឱ្យការអនុវត្តថវិកាដំណើរការសាលារៀនមានប្រសិទ្ធភាព និងជួយជំរុញដល់ការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យនិងឯកភាពដូចខាងក្រោម ÷

១- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បង្វែរថវិកាដំណើរការសាលារៀនចំនួន ០២ លើកក្នុងមួយឆ្នាំ ចូលក្នុងគណនីធនាគារសាលារៀនសាធារណៈទូទាំងប្រទេស ស្របតាមលិខិតលេខ ១០០៤៣ សហវ.អថ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដែលការបង្វែរលើកទី ១ គឺនៅក្នុងខែមករា និងលើកទី ២ នៅក្នុងខែមិថុនា ។

២- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បង្វែរថវិកាចំនួន **៤ ០៥០ ០០០រៀល (បួនលានប្រាំម៉ឺនរៀលគត់)** ចូលគណនីធនាគារសាលារៀនសាធារណៈ នៅដើមខែមករា ឆ្នាំ២០១៩ ដើម្បីឱ្យសាលារៀនសាធារណៈអាចដកសាច់ប្រាក់ផ្ទាល់សម្រាប់ទិញកុំព្យូទ័រមួយគ្រឿង និងព្រីនធ័រមួយគ្រឿង ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាគុណភាព និងសង្គតិភាព ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំយថាប្រភេទស្តង់ដារអប្បបរមានៃបរិក្ខារនេះឱ្យបានច្បាស់លាស់ ។

18.01.2019

មកដល់ក្រសួង ស.ហ.វ
ថ្ងៃ 17 ខែ 01 ឆ្នាំ 2019
ម៉ោង ... ចុះលេខ 286



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៣- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បង្វែរថវិកាអាហារូបករណ៍ចូលគណនីធនាគារសាលារៀនសាធារណៈដោយផ្ទាល់ ដើម្បីឧបត្ថម្ភសិស្សក្រីក្រជួបការលំបាកនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ។ លក្ខខណ្ឌផ្សេងៗទៀត ត្រូវអនុវត្តស្របតាមអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១៥ ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ និងប្រកាសអន្តរក្រសួងលេខ ១២៤៥ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានយន្តការផ្ទៃក្នុងច្បាស់លាស់ដើម្បីឱ្យមានតម្លាភាព និងធានាថាសាច់ប្រាក់អាហារូបករណ៍ដែលនៅសល់ជាយថាហេតុពីការបើកផ្ដល់ជូនសិស្សអាហារូបករណ៍ ត្រូវបានផ្ទេរចូលថវិការដ្ឋវិញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម** ជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ